# ថ្នាំកប់អង្គររាបក្នុងពិធីកោរជុក

អ្នកស្រាវជ្រាវយល់ថា "កោរជុក" ឬ "កោរកំប៉ោយ" ជាពិធីឆ្លងវ័យក្នុងដំណើរជីវិតមនុស្សខ្មែរ ពោលគឺឆ្លងពីវ័យកុមារភាពត្រៀមខ្លួនចូលភាពពេញវ័យ។[1] បើតាមចំណាំគេច្រើនធ្វើពិធីឱ្យក្មេងទាំងប្រុសទាំងស្រីអាយុចាប់ពី៩ឆ្នាំ ឬ១១ឆ្នាំ ដល់១៣ឆ្នាំ (រូបលេខ១)។ មកដល់សព្វថ្ងៃ ទំនៀមនេះនៅសង្កេតឃើញបន្តប្រារព្ធតាមភូមិមួយចំនួន ស្ថិតនៅតំបន់អង្គរ ខេត្តសៀមរាប ធ្វើក្នុងរវាងខែមាឃ និងខែផល្គុន (កុម្ភៈ-មីនា)។ សោតឯដំណើរនៃពិធីមានការរៀបចំកិច្ចតូចធំ និងមានរណ្តាប់ច្រើនប្រការដែរ រាប់តាំងពីធ្វើនំ សង់រោងពិធី ចាក់ចេកតុបតែង ធ្វើពានកោរសក់ឬពានម៉ា ធ្វើបាយសី និងគ្រឿងសក្ការបូជាផ្សេងៗ។ ក្នុងចំណោមនោះ អង្គររាបក៏ជារណ្តាប់យ៉ាងសំខាន់ ដែលរៀបចំជាពិសេសសម្រាប់សាមីពិធី ហៅថា "កិច្ចដេកអង្គររាប"។ តាមការសង្កេត គេឃើញក្នុងអង្គររាបតែងមានកប់រុក្ខជាតិ ឬហៅថាថ្នាំច្រើនមុខ ហើយក្នុងអត្ថបទនេះខ្ញុំសូមលើកករណីពិធីកោរជុក នៅភូមិត្នោតជ្រុំ ស្ថិតក្នុងស្រុកពួក ខេត្តសៀមរាប មករៀបរាប់ដូចខាងក្រោម។



រូបលេខ២ ក្មេងប្រុសស្រីមានអាយុផ្សេងៗគ្នា ដែលបានធ្វើពិធីកោរជុក

[1] អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាប់ដឹប, ២០១៤, ទំ.១១-២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមសម្គាល់នៅក្នុងពិធីកោរជុក គេតែងរៀបចំធ្វើកិច្ចដេកអង្គរពាបនៅវេលាស្ទើរតែពាក់កណ្តាលអាធ្រាត្រ ដោយភ្ជាប់ទៅនឹងកិច្ចហៅព្រលឹងសក់ឱ្យសាមីពិធី។ ប៉ុន្តែមុននឹងរៀបរាប់អំពីថ្នាំដែលកប់ក្នុងអង្គរពាបនោះ ខ្ញុំសូមបញ្ជាក់ថាអង្គរពាប គឺជាកញ្ចប់អង្គរខ្ចប់នឹងសំពត់ស ហើយបរិមាណអង្គរនោះត្រូវវាល់ច្រើនបែបយ៉ាង មានក្បួនច្បាប់ ឬទម្លាប់រផ្លាស់រផ្លាល់ខុសគ្នាពីអាចារ្យម្នាក់ទៅម្នាក់ដែរដូចជា តក់ នាឡិ ក្លាប់ ចិប ច្បិច ថ្លិត និងផ្ទាត់ជាដើម។ មុននឹងវាល់អង្គរតាមក្បួនខ្នាតខាងលើ លោកអាចារ្យត្រូវរាយស្លឹកឈូកលើសំពត់សជាមុនសិន (រូបលេខ២-៣)។ បើពិនិត្យជាក់ស្តែង គេឃើញស្លឹកឈូកខ្លះពេញរូបរាង ស្លឹកឈូកខ្លះហែកត្រឹមពាក់កណ្តាល ហើយបើរាប់ចំនួនឃើញមានប្រហែលជាង១០សន្លឹកប៉ុណ្ណោះ តែបើយកការសិក្សារបស់អ្នកស្រាវជ្រាវមកបញ្ជាក់ គឺស្លឹកឈូកនោះគេត្រូវរៀបចំនួន២១សន្លឹក ដែលតំណាងឱ្យគុណឪពុក។[2]



រូបលេខ២-៣ លោកអាចារ្យរៀបចំក្រាលសំពត់ស និងរាយស្លឹកឈូក

បន្ទាប់ពីលោកអាចារ្យក្រាលសំពត់ស និងរៀបស្លឹកឈូករួចរាល់ហើយ ទើបចាប់ផ្តើមវាល់អង្គរដាក់លើស្លឹកឈូកតាមក្បួនខ្នាតដូចរៀបរាប់ខាងលើគឺ ចំនួន១២តំណាងឱ្យគុណម្តាយ ៩តំណាងគុណគ្រូ ៧តំណាងគុណបង និងចំនួនតាមអាយុសាមីខ្លួនកោរជុកនោះ(រូបលេខ២៨)។ សូមបញ្ជាក់ថាជាទូទៅក្មេងមានអាយុ១០ឆ្នាំឡើងទើបលោកអាចារ្យឱ្យដេកអង្គរពាប។ ដូច្នេះក្រោយវាល់អង្គរតាមក្បួនខ្នាតគ្រប់ចំនួនហើយ លោកអាចារ្យក៏យកត្រល់មួយមានចងស្លឹកឈូក និងចិញ្ចៀនទៅកប់ក្នុងអង្គរនោះ (រូបលេខ២៩)។ ចិញ្ចៀនចងភ្ជាប់នឹងត្រល់នេះ មានការពន្យល់ថាតំណាងឱ្យភោគផល ពោលគឺតំណាងឱ្យការគព

[2] អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាប់ដឹប, ២០១៨, ទំ.១៧

ប្រសព្វគ្នារវាងភេទស្រី (ចិញ្ចៀន) និងភេទប្រុស (ត្រល់)ៗ[3] ម្យ៉ាងទៀតមានការបកស្រាយខ្លះបញ្ជាក់ថា កិច្ចដេកអង្ករាប គឺធ្វើឱ្យសាមីពិធីទទួលបាននូវកម្លាំងពលំ និងសេចក្ដីសុខដែលកើតពីគ្រឿងមង្គលទាំងឡាយកប់ក្នុងអង្ករ។ ដោយឡែកចំពោះឈ្មោះរុក្ខជាតិ ឬថ្នាំប្រើសម្រាប់កប់ក្នុងអង្ករាបនោះ យ៉ាងហោចមាន៩មុខ ហើយខ្លះឃើញសរសេរឈ្មោះភ្ជាប់ជាមួយផង។ ប៉ុន្តែមុននឹងរាយថ្នាំទាំងអស់ អាចារ្យគូរបែងក្រឡាលើអង្ករម្ដងជាពីរដងរួចទើបយកថ្នាំដាក់រាយតាមប្រឡោះទិសនីមួយៗ ដែលមានកំណាត់ដើមស្បូវភ្លាំងខណ្ឌចែក។ នៅទិសខាងកើតដាក់ក្រវាញ ទិសអាគ្នេយ៍ដាក់ក្លាំពូ ទិសខាងត្បូងដាក់ជីប្លី ទិសនិរតីដាក់សម្បូរវែង ទិសខាងលិចដាក់សណ្ដែកមាស ទិសពាយ័ព្យដាក់ដំបែរ ទិសខាងជើងដាក់ស្វាត្រក ទិសឦសានដាក់ម្រេច ហើយនៅកណ្ដាលដាក់ផ្កាចន្ទន៍។ (រូបលេខ២៦-២៧)។ សូមបញ្ជាក់ថាអង្ករាបនេះ បើនៅតំបន់អង្គរមានប្រើក្នុងពិធីផ្សេងទៀតដែរដូចជាបួសនាគ អាពាហ៍ពិពាហ៍ និងចម្រើនអាយុជាដើម ហើយរបៀបរៀបចំក៏អាចប្លែកគ្នាខ្លះ។



រូបលេខ២៨ លោកអាចារ្យវាល់អង្ករតាមខ្នាតផ្សេងៗ



រូបលេខ២៩ ចិញ្ចៀននិងត្រល់កប់ក្នុងអង្ករ (ក្នុងរង្វង់)





រូបលេខ២៦-២៧ ថ្នាំកប់ក្នុងអង្ករាប

[3] ស សុខធីតា, ២០១៣-២០១៤, ទំ.២០-២៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្រោយពេលរៀបចំវេចខ្ចប់អង្គរាបរួចស្រេច ដាក់នៅកណ្ដាលទីប្រារព្ធកិច្ចហើយ លោកអាចារ្យ និងចាស់ទុំចាប់ផ្ដើមបង្វិលពពិល។ ប៉ុន្តែមុននឹងបង្វិលពពិល លោកអាចារ្យដឹកនាំនមស្ការសង្ខេប ដោយមានសាមីពិធីចូលរួមផង។ បន្ទាប់មកទើបអុជទៀនបិទភ្ជាប់នឹងពពិល បង្វិល៣ជុំតាមទិសប្រទក្សិណជុំវិញអង្គរាប និងក្មេងៗសាមីពិធី។ បើនិយាយហួសទៅបន្តិចអត្ថន័យពពិលនិងទៀន ក៏ពុំខុសពីត្រល់និងចិញ្ចៀន ដូចរៀបរាប់ខាងលើដែរ ដ្បិតកិច្ចធ្វើក្នុងន័យជានិមិត្តរូបរីកចម្រើនដុះដាលលូតលាស់ជាមង្គល បុរាណតែងមានវត្ថុពិសិដ្ឋជានិមិត្តរូបដូច្នេះ។[4] លុះបង្វិលពពិលគ្រប់៣ជុំហើយ សាមីពិធីត្រូវដេកលើអង្គរាបនោះ (រូបលេខ៩) ចំណែកចាស់ទុំបន្តកិច្ចហៅព្រលឹងសក់ ហើយក្មេងៗជាសាមីពិធីដេកលង់លក់កើយអង្គរាបរហូតដល់ភ្លឺ (រូបលេខ១០)។[5]



រូបលេខ៩-១០ កិច្ចបង្វិលពពិល និងហៅព្រលឹងសក់ដេកអង្គរាប

ពាក់ព័ន្ធនឹងថ្នាំកប់ក្នុងអង្គរាប បើមកមើលសេចក្ដីក្នុងក្រាំង និងវាំនបុរាណប្រើសម្រាប់រៀបចំកិច្ចជាមង្គលខ្មែរ ដែលមាននិយាយដល់ថ្នាំកប់អង្គរាបនោះដែរ គេឃើញរៀបរាប់ឈ្មោះរុក្ខជាតិប្រហែលជិត២០មុខ។[6] រុក្ខជាតិខ្លះឈ្មោះដូចរុក្ខជាតិជាថ្នាំរបស់អ្នកស្រុកនៅតំបន់អង្គរប្រើ តែរុក្ខជាតិខ្លះមានឈ្មោះខុសគ្នាដូចជា ក្រវាញ ក្ដាំពូ ទេពទារូ សម្បុរល្វែង ដីប្ញី ស្រូវគង់ សណ្ដែកមាស ម្រេច ខ្ទឹម ដំបែ ស្លឹកឈូក ស្លឹកចារ ស្លឹកញ្ញោ ស្លឹក

---

[4] លឹម កន្និដ្ឋា, ២០០៧-២០០៨, ទំ.២៥-២៨

[5] ថាន់ មនោមយិទ្ធិ, “កោរជុក” ផ្សាយលើគំណា https://ams.com.kh/khmercivilization/detail/493 (១៥ មេសា ២០២១)

[6] សូមអាន៖ វាំនចុះលេខសារពើភណ្ឌd957 រក្សានៅបណ្ណាល័យសាស្ត្រាស្លឹករឹតក្នុងវត្តឧណ្ណាលោម

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ខ្ញែងគង់ ស្លឹកល្វា ស្លឹកឫស្សី ស្លឹកបន្ទាស្អិត ស្លឹកកំពូលបាយ និងស្លឹកសំបួរមាស។ ចំពោះរុក្ខជាតិមួយចំនួនក្នុងចំណោមរុក្ខជាតិដូចរាប់មកខាងលើ ខ្លះក៏ឃើញមានដុះលូតលាស់សព្វថ្ងៃ ខ្លះប្រទះឃើញដោយកម្រ តែខ្លះពុំដែលប្រទះឃើញផង (រូបលេខ១១)។




រូបលេខ១១ រុក្ខជាតិខ្លះៗក្នុងចំណោមរុក្ខជាតិជាច្រើនដែលប្រើធ្វើថ្នាំកប់អង្គរាប

ជារួមមកក្នុងបណ្ដារុក្ខជាតិទាំងឡាយដូចរៀបរាប់មកខាងលើ គេឃើញរុក្ខជាតិខ្លះប្រើផ្សំគ្នាជាថ្នាំបុរាណកបនឹងជំងឺផ្សេងៗដូចជា សម្បកទេពទារូមានក្លិនប្រហើរ ប្រើផ្សំជាមួយសម្បុរល្វែងប្រើជាថ្នាំក្ដៅ។ ចំណែកឯផ្លែដីប្លី គឺជារុក្ខជាតិកម្រប្រទះឃើញសព្វថ្ងៃ តែផ្លែដីប្លីទុំគេអាចហាលឱ្យស្ងួតសម្រាប់ស្ត្រីមានគភ៌ដាំទឹកទទួលទាន។[7] លើសពីនោះទៅទៀត ចំពោះស្លឹកញ្ញោសព្វថ្ងៃឃើញប្រើក្នុងទំនៀមក្សត្រ ដែល**ព្រះករុណាជាអម្ចាស់** ទ្រង់តែងសៀតព្រះកាណ៌ យាងជាព្រះរាជាធិបតីនៅក្នុងព្រះរាជពិធីសំខាន់ៗផងដែរ៕

7 អាំង ជូលាន, ២០០៧-២០០៨, ទំ.៩៦-៩៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ថាន់ មនោមយិទ្ធិ

២០២១ "កោរជុក" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/493 (១៥ មេសា ២០២១)

លឹម កន្និដ្ឋា

២០០៧-២០០៨, "ពពិល", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ ៣, ទំ.២៥-២៨, Friends of Khmer Culture, ភ្នំពេញ

ស សុខធីតា

២០១៣-២០១៤, "គោគជល", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២៩, ទំ.២០-២៨, យសោធរ, ភ្នំពេញ

អាំង ជូលាន

២០០៧-២០០៨, "ដីប្ញី", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២៣, ទំ.៩៦-៩៨, Friends of Khmer Culture, ភ្នំពេញ

អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប

២០១៤, *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ*, យសោធរ, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត